ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែសីហា ឆ្នាំ២០១៣

## I- សភាពការណ៍រួម

ក្នុងខែសីហា ឆ្នាំ២០១៣នេះ ស្ថានភាពអាកាសធាតុទទួលឥទ្ធិពលពីជ្រលងសម្ពាធទាប ផ្ទៃមេឃមានពពកពីតិចទៅច្រើន ខ្យល់បក់ពីទិសនិរតីនិងមានភ្លៀងធ្លាក់តិចនិងច្រើននៅតាមតំបន់មួយចំនួននៃរាជធានី ខេត្ត។ ប្រជាកសិករទូទាំងប្រទេសបាននិងកំពុងខិតខំជំរុញការងារបង្កបង្កើនផលគ្រប់មុខដំណាំ ជាពិសេសការងារបង្កបង្កើនផលស្រូវមានជាអាទិ៍ ការរៀបចំដី ភ្ជួររាស់ សាប-ព្រោះ ដក-ស្ទូង ស្មើនឹង៩៥,៥៣ភាគរយ នៃផែនការដាំដុះ ២.៣៩៩.៦៣៧ហិកតា។ ដោយឡែកទឹកទន្លេមេគង្គមានសភាពកើនឡើងជាងឆ្នាំមុន បើប្រៀបធៀបរយៈពេលដូចគ្នា។

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៣

១.១.១ ដំណាំស្រូវ

-ផ្ទៃដីភ្ជួររាស់សរុបចំនួន២.៩៨៨.៩៧៣ហិកតា (ក្នុងនោះគោ-ក្របីចំនួន៩១១.១៨២ហិកតា ស្មើនឹង៣០,៤៨% និងគ្រឿងយន្តចំនួន២.០៧៧.៧៩១ហិកតា ស្មើនឹង៦៩,៥២%) លើសឆ្នាំមុន២៤៤.០៥៧ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ២៦១.៧៥៩ហិកតា

-ផ្ទៃដីសាបសរុបចំនួន១៥៦.៥២៦ហិកតា តិចជាងឆ្នាំមុន៨.២២៨ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ១៣៨.៤៣៣ហិកតា

-ផ្ទៃដីស្ទូងនិងពង្រោះសរុបចំនួន២.២៩២.៣៤៦ហិកតា ស្មើនឹង៩៥,៥៣% នៃផែនការ២.៣៩៩.៦៣៧ហិកតា លើសឆ្នាំមុន២១៩.៥៤៧ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ២៤៦.២៩១ហិកតា

- ស្រូវស្រាលចំនួន ៥៧៩.៦២១ហិកតា (ក្នុងនោះស្រូវបង្កើនរដូវចំនួន២២៤.៩៧១ហិកតា) លើសឆ្នាំមុន ២.០៥៣ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ៧៥.២៨២ហិកតា
- ស្រូវកណ្តាលចំនួន ១.០៨៦.៦០៥ហិកតា លើសឆ្នាំមុន ១៧៣.២៤៨ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ១៥១.២០៧ហិកតា
- ស្រូវធ្ងន់ចំនួន ៥១៣.៤០៩ហិកតា លើសឆ្នាំមុន ៤៧.៤២១ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ៤៦.១៦៦ហិកតា



អាសយដ្ឋាន លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

• ស្រូវចម្ការចំនួន ៤៦.៧៥៤ហិកតា តិចជាងឆ្នាំមុន ៣៣៨ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ ២.១០៥ហិកតា

• ស្រូវឡើងទឹកចំនួន ៦៥.៩៥៧ហិកតា តិចជាងឆ្នាំមុន ២.៨៣៧ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ ២៤.២៥៧ហិកតា។

-ការងារប្រមូលផលស្រូវស្រាលដើមរដូវក្នុងខែសីហានេះសម្រេចបានលើផ្ទៃដីចំនួន ១៦៤.៣០៩ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ៦១០.២០៥តោន និងទិន្នផលជាមធ្យមចំនួន ៣,៧១៤តោនក្នុងមួយហិកតា

-មកទល់ពេលនេះ ល្បឿនការងារដាំដុះដំណាំស្រូវសម្រេចបាន ៩៥,៥៣% នៃផែនការនិងមានសភាពលឿនជាងឆ្នាំមុន។ ជាមួយគ្នានោះ ទឹកជំនន់ទន្លេមេគង្គនិងទឹកភ្លៀងបានបង្កផលប៉ះពាល់ដល់សំណាបចំនួន ១១ហិកតា និងសន្ទូង-ពង្រោះចំនួន២៥.៣៦០ហិកតា។ ដោយឡែកនៅស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ បានជួបកង្វះខាតទឹកលើសំណាបចំនួន ១១២ហិកតា និងសន្ទូង-ពង្រោះចំនួន ១.០៦០ហិកតា។

១.១.២ ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន ៦០១.៣៧០ហិកតា ស្មើនឹង ១១៦,២៦ភាគរយ នៃផែនការសរុប ៥១៧.២៦០ហិកតា លើសឆ្នាំមុន ៣៣.៧៧១ហិកតា ក្នុងនោះមាន÷

-ផ្ទៃដីដាំពោតចំនួន១៤៨.៥០៦ហិកតា តិចជាងឆ្នាំមុន៧.២០២ហិកតា ក្នុងនោះផ្ទៃដីដាំពោតក្រហមមាន ១៣០.០៥៩ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន ៣៧៩.២៨១ហិកតា លើសឆ្នាំមុន ៤៣.៣៦០ហិកតា

-ផ្ទៃដីដំឡូងជ្វាចំនួន ៤.១៩៩ហិកតា លើសឆ្នាំមុន ៤១ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន ២៦.៨១១ហិកតា លើសឆ្នាំមុន ៨២២ហិកតា

-ផ្ទៃដីសណ្ដែកបាយចំនួន ៤២.៥៧៣ហិកតា តិចជាងឆ្នាំមុន ៣.២៥០ហិកតា ។

១.១.៣ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន ១២៥.២៥២ហិកតា ស្មើនឹង ៨១,១១ភាគរយ នៃផែនការសរុប ១៥៤.៤២៩ហិកតា លើសឆ្នាំមុន ៤.៣៩៧ហិកតា ក្នុងនោះមាន÷

-ផ្ទៃដីសណ្ដែកដីចំនួន ១៦.៧៧៩ហិកតា លើសឆ្នាំមុន ២.៤៤៩ហិកតា

-ផ្ទៃដីសណ្ដែកសៀងចំនួន ៥៦.៩៤៩ហិកតា លើសឆ្នាំមុន ៤.៩៤៥ហិកតា

-ផ្ទៃដីល្ងចំនួន ៣៣.៦៤៦ហិកតា តិចជាងឆ្នាំមុន ២.៨៩៤ហិកតា

-ផ្ទៃដីអំពៅចំនួន ១៧.៥៧៩ហិកតា តិចជាងឆ្នាំមុន ១២៦ហិកតា

-ផ្ទៃដីក្រចៅចំនួន ២១៦ហិកតា តិចជាងឆ្នាំមុន ២០ហិកតា

-ផ្ទៃដីថ្នាំជក់ចំនួន ៨៣ហិកតា លើសឆ្នាំមុន ៤៣ហិកតា។

## ២ ផ្នែកព្រៃឈើ

### ២.១ ការងារចំណូលព្រៃឈើ

-ចំណូលពីផលព្រៃឈើចូលថវិកាជាតិសរុបចំនួន៤០.៥៣១.៣៥៨.៨៧៣រៀល ដែលក្នុងនោះចំណូលបានមកពីផលទុនពីការលក់-ជួលទ្រព្យសម្បត្តិនិងសេវាចំនួន៣២.៥៤២.៣៣៧.១៧៧រៀល និងចំណូលបានពីការផាកពិន័យឈើដែលបានមកពីការបង្រ្កាបបទល្មើសចំនួន៧.៩៨០.២២១.៦៩៦រៀល។

### ២.២ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ធ្វើសារពើភណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើជូនក្រុមហ៊ុនចំនួន០១

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP)ចេញពីព្រៃគុបផ្តល់ផលក្រៅពីព្រៃសម្បទាន÷ ឈើហ៊ុបមូលសរុបចំនួន ១១.៧៧១,០៨៧ម៣ ឈើអារចំនួន ៣.៤១៤,៦៤៦ម៣ ឈើជ្រុងចំនួន ៩១៥,៥១៩ម៣ កូនឈើចំនួន ១៩.៣៣២ដើម អុសចំនួន ៦.២៧០ស្ទែរ និងជ័រទឹកចំនួន១៣០,១០៨តោន។

## ២.៣ ការងារអភិរក្សសត្វព្រៃ

-ជំរឿនសត្វស្លាបដែលមាននៅក្នុងតំបន់អភិរក្សបឹងព្រែកល្ពៅចំនួន១.៦៥៦ក្បាល តំបន់អភិរក្សអន្លង់ព្រីងចំនួន ១.០១៩ក្បាល តំបន់អភិរក្សអាងត្រពាំងថ្មចំនួន៤៥.០១០ក្បាល និងតំបន់អភិរក្សសត្វខ្សឹបកំពង់ធំ-សៀមរាបចំនួន ៦៦.២១៥ក្បាល

-រកឃើញនិងការពារសម្បុកពងកូនសត្វក្រៀលចំនួន១៦សម្បុក ត្រយ៉ងយក្សចំនួន១៣សម្បុក និងទាព្រៃស្លាបស ០១សម្បុក នៅព្រៃការពារព្រះវិហារ។ ត្រយ៉ងយក្សចំនួន០១សម្បុក និងត្រយ៉ងចង្កិកសចំនួន១១៨ក្បាល នៅខេត្តស្ទឹងត្រែង ព្រមទាំងត្រយ៉ងចង្កិកសចំនួន៣០៦ក្បាល និងត្រយ៉ងយក្សចំនួន០២សម្បុក នៅតំបន់សៀមប៉ាង

-រៀបចំអាហារដ្ឋានត្មាតនៅតំបន់វាលគ្រួសនៃព្រៃការពារព្រះវិហារចំនួន០១លើកសរុបចំនួន៥១ក្បាល និងតំបន់សៀមប៉ាងមានចំនួន៦៣ក្បាល

-បង្កាត់ពូជក្រពើសុទ្ធនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ សត្វក្រពើភ្នំពូជសុទ្ធបង្កាត់ចំនួន០១សម្បុក មាន០៩ពង

-ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាសរុបចាប់ពីដើមឆ្នាំ សត្វចំណូលថ្មីចំនួន៥១៥ក្បាល សត្វកើតថ្មីចំនួន៥១ក្បាល សត្វដោះលែងចំនួន២៤២ក្បាល សត្វស្លាប់ចំនួន៩១ក្បាល ព្យាបាលសត្វចំនួន១៨៩ក្បាល យកសំណាកទៅពិសោធន៍ចំនួន២៥៨ក្បាល ធ្វើឲ្យសន្លប់ចំនួន១២៦ក្បាល ទម្លាក់សត្វល្អិតចំនួន៥២៥ក្បាល វះកាត់សាកសពសត្វចំនួន៣១ក្បាល ដាក់លេខកូដចំនួន១៧ក្បាល ចាក់វ៉ាក់សាំងចំនួន៤៦៩ក្បាល ជួសជុលផ្លូវចំនួន២០២.៥៤៨ម២ និងឆ្ការអនាម័យព្រៃ១៥៤.៤៤៤ម២ សាងសង់ទ្រុងសត្វនិងអគារផ្សេងៗចំនួន៣.៥៩៧ម២ សាងសង់របងហ៊ុមព័ទ្ធនិងទ្រុងសត្វថ្មីលើដីចំនួន១៣.២២៣ម២ សាងសង់សំណង់ផ្សេងៗចំនួន៩៧៥ម២ ដាំកូនឈើចំនួន ១.២៥៤ដើម បណ្តុះផ្កាលម្អ(ផ្កាក្រដាស)ចំនួន៣.២០៨ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៩.៣៣៥នាក់

-ក្រុមហ៊ុនចំនួន ០៧ កំពុងចិញ្ចឹមសត្វក្តាមចំនួន៧៦.១២៥ក្បាល។

## ២.៤ ការងារដាំដើមឈើ

-ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន០៩របស់រដ្ឋបាលព្រៃឈើ បណ្តុះកូនឈើគ្រញូងបានគ្រប់ផែនការ ឈូសឆាយដីព្រៃបានចំនួន២០០ហិកតា ដាំកូនគ្រញូងបានចំនួន១៤០ហិកតា និងស្ថានីយដាំឈើចំនួន១០ លើផ្ទៃដីចំនួន ៣.៨៦៨ហិកតា ត្រូវធ្វើការថែទាំនិងការពារជាប្រចាំ។ ដោយឡែកចម្ការឆ្នាំទី១ឬឆ្នាំទី២ ដែលទទួលរងការខូចខាតដោយភ្លើងឆេះកំពុងរៀបចំដាំបំពេញផែនការឡើងវិញនៅតាមស្ថានីយដាំឈើមានក ភ្នំតូលេន ក្បាលឆាយ និងក្រសាំង

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចបានឈូសឆាយដីព្រៃចំនួន ២.៧៣១ហិកតា និងដាំកូនឈើនិងកូនកៅស៊ូចំនួន ១.៣៦៥ហិកតា

-ថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើអនុវត្ត÷ កូនឈើសល់ស្តុកក្នុងឆ្នាំ២០១២ចំនួន៧៥៣.១៩៧ដើម កូនឈើបណ្តុះក្នុងឆ្នាំ២០១៣សរុបចំនួន៣៩២.៣៨៤ដើម និងចែកចាយកូនឈើក្នុងឆ្នាំ២០១៣សរុបចំនួន៣៦.៥២១ដើម

-សួនអាពាហ៍ពិពាហ៍១ទីតាំងមានទំហំដី៥៣ហិកតា ស្ថិតនៅភូមិ១ ឃុំឡាមិញ ស្រុកបរកែវ ខេត្តរតនគីរី

-ពិធីបុណ្យរុក្ខទិវា ៩ កក្កដា ២០១៣ ប្រារព្ធធ្វើនៅស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើក្បាលឆាយ ដែលស្ថិតនៅក្នុងភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដោយមានការដាំដុះប្រភេទឈើគ្រញូង គគីរ និងឈើទាលលើផ្ទៃដីចំនួន ២០ហិកតា និងមានប្រជាពលរដ្ឋចូលរួមចំនួន ៧.៥០០នាក់

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន Think Biotech(Cambodia) Co., Ltd បានឈូសឆាយសម្អាតដីចំនួន

៤០០ហិកតា ផលិតពូជកូនឈើចំនួន២.០០០.០០០ដើម ដាំដុះកូនឈើប្រភេទអាកាស្យាហាយប្រីតចំនួន២០០ហិកតា និងសាងសង់រោងចក្រកែច្នៃឈើបានប្រមាណ៥០%

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន អូជី (ខេមបូឌា) ផ្លេនថេសិន ហ្វរីស ខមភេនី លីមីធីត បានកាប់ឆ្ការនិងឈូសឆាយសម្អាតដីចំនួន៨៥ហិកតា ផលិតពូជកូនឈើចំនួន៦៥០.០០០ដើម និងដាំដុះកូនឈើក្នុងឡូត៍ពិសោធន៍ដូចជា ប្រេងខ្យល់ ស្រល់ និងអាកាស្យាហាយប្រីតចំនួន២៥ហិកតា

-ដំណាំកសិរុក្ខកម្ម មានឡូត៍ស្រាវជ្រាវប្រព័ន្ធកសិរុក្ខកម្មទំហំ ៥ហិកតា ដែលមានទីតាំងនៅខេត្តកំពង់ធំ កំពុងដំណើរការឈូសឆាយបាន០៥ហិកតា។

**២.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម**

**២.៥.១ ការងារពាណិជ្ជកម្មនាំចេញ នាំចូល**

-ពិនិត្យឯកសារស្នើសុំពាក់ព័ន្ធនឹងការនាំចេញនាំចូលចំនួន០៤ក្រុមហ៊ុន

-ផ្តល់អាជ្ញាប័ណ្ណនាំចេញឈើកែច្នៃគ្រប់ប្រភេទជូនក្រុមហ៊ុនចំនួន០៣។

**២.៦ ការងារនីតិកម្មនិងវិវាទ**

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃសរុបចំនួន ១០១ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើហ៊ុបមូលចម្រុះប្រភេទចំនួន១៣,៣០៦ម៣ ឈើអារចំនួន១៨៥,៧៥២ម៣ ឈើក្រាក់គ្រញូងចំនួន១៥,១០៣ម៣ កូនឈើចំនួន៣៨៧ដើម ឈើជន្លង់ម្រេចចំនួន៤៧ដើម ឫស្សីចំនួន១.៣៧២ដើម អុសចំនួន៣៥ស្ទេរ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន២១៩,១០គ.ក្រនិង៦១១ក្បាល ក្រពះប្រម៉ាចំនួន១០ក្រពះ រថយន្តចំនួន៤៤គ្រឿង ត្រាក់ទ័រចំនួន០១គ្រឿង ម៉ូតូចំនួន១៥គ្រឿង រទេះកង់ឡានចំនួន០៥គ្រឿង ម៉ាស៊ីនផ្សេងៗចំនួន០១គ្រឿង រណារយន្តចំនួន០១គ្រឿង និងសម្ភារផ្សេងៗទៀត ព្រមទាំងដកហូតដីព្រៃឈើចំនួន ៦២៩,០៩២ហិកតា

-ចុះស្រង់ស្ថិតិដីព្រៃឈើដែលបានកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើកម្មសិទ្ធិចំនួន ១.៤៦២,៤៩៥ហិកតា និងដកហូតដីព្រៃដែលបានកាប់រានសរុបចំនួន១.៨០៦,៥២០ហិកតា ។

## ៣ ផ្នែកជលផល

**៣.១ អាជីវកម្មនេសាទ**

**៣.១.១ នេសាទទឹកសាប**

-ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១២-២០១៣(បញ្ចប់រដូវ) សរុបបានចំនួន៨.៥០០តោន ស្មើ៨៥%នៃផែនការ ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៩១.៥០០តោន

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៣ *ក្នុងខែចំនួន១៥.០០០តោន* សរុបបានចំនួន១៦០.០០០តោន ស្មើ ៥៣,៣៣% នៃផែនការ៣០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣២.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៣ *ក្នុងខែចំនួន១០.០០០តោន* សរុបបានចំនួន៧០.០០០តោន ស្មើ៤៦,៦៧% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២៨.០០០តោន ។

**៣.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៣**

-*ក្នុងខែចំនួន៨.០០០តោន* សរុបបានចំនួន៦៦.០០០តោន ស្មើ៧៣,៣៣%នៃផែនការ៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០តោន។

### ៣.២ វារីវប្បកម្ម

-ការចិញ្ចឹមត្រីនិងបង្គា *ក្នុងខែចំនួន៨.០០០តោន* សរុបបានចំនួន៥៨.០០០តោន ស្មើ៧២,៥០%នៃផែនការ ៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.០០០តោន

-ការចិញ្ចឹមក្រពើ *ក្នុងខែចំនួន១០.០០០ក្បាល* សរុបបានចំនួន១៨០.០០០ក្បាល ស្មើ៩០% នៃផែនការ ២០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១៥.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ *ក្នុងខែចំនួន១០.០០០.០០០កូន* សរុបបានចំនួន៩០.០០០.០០០កូន ស្មើ៦០% នៃផែនការ ១៥០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៨.០០០.០០០កូន ។

### ៣.៣ ការកែច្នៃផលនេសាទ

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១២-២០១៣ *ក្នុងខែចំនួន៥.០០០តោន* សរុបបានចំនួន៤៥.០០០តោន ស្មើ៤៥% នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣០.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៣ *ក្នុងខែចំនួន៥០០តោន* សរុបបានចំនួន៥.៥០០តោន ស្មើ៩១,៦៧% នៃផែនការ៦.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤០០តោន

-ការផលិតទឹកត្រី *ក្នុងខែចំនួន៣.០០០.០០០លីត្រ* សរុបបានចំនួន៤៣.០០០.០០០លីត្រ ស្មើ៧១,៦៧% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០.០០០លីត្រ។

### ៣.៤ ការនាំចេញផលនេសាទ

-ផលនេសាទស្រស់ *ក្នុងខែចំនួន៥០០តោន* សរុបបានចំនួន៧.៥០០តោន ស្មើ៣៧,៥០% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.១០០តោន

-ផលនេសាទកែច្នៃ *ក្នុងខែចំនួន៥០០តោន* សរុបបានចំនួន៤.០០០តោន ស្មើ៤០% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៤០០តោន។

### ៣.៥ ការការពារប្រភពធនធានជលផល

-កំណត់ហេតុបទល្មើស សរុបចាប់ពីដើមឆ្នាំចំនួន ១.៧៧១ករណី ដែលកើតមាននៅតំបន់ទឹកសាប ១.៧១០ករណី និងតំបន់សមុទ្រ ៦១ករណី ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន ៦៤ករណី គឺតំបន់ទឹកសាប៤០ករណីនិងតំបន់សមុទ្រ២៤ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៣.៦ ការប្រមូលថវិកា

-ចំណូលពីវិស័យជលផល *ក្នុងខែចំនួន៥០.៦២០.០០០រៀល* សរុបបានចំនួន១.៥៨៧.៦០៤.៥៩១រៀល ស្មើ៥៣,៨៧% នៃផែនការ២.៩៤៧.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.១០៧.៣២៣.៥៥៩រៀល។

## ៤ ផ្នែកផលិតកម្មនិងបសុពេទ្យបាល

### ៤.១ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

-ចាក់ថ្នាំការពារជំងឺឆ្លងលើគោ ក្របី ជំងឺសារទឹកចំនួន ៣៦១.៨៧៩ក្បាល ជំងឺអុតក្តាមចំនួន ៨៦.៤១៩ក្បាល និងជំងឺបូសខ្យល់ចំនួន ២.១៨៧ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន ១០.៣៥៤ក្បាល ជំងឺប៉េស្តចំនួន ១៥.៣៧២ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន ៨.០៥១ក្បាល ជំងឺអុតក្តាមចំនួន ៤៤៦ក្បាល ជំងឺអូហ្យេស្គីចំនួន ២.៩៥៤ក្បាល ជំងឺរាគកូនជ្រូកចំនួន ២.៥៤៥ក្បាល ជំងឺកញ្ជ្រឹលចំនួន ៨៣ក្បាល ជំងឺជាតិដែកចំនួន ១.០៧៩ក្បាល និងជំងឺផ្លូវដង្ហើមចំនួន ៧៦ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន ១៧.៣៨៤ក្បាល ជំងឺញីវកាសចំនួន ៤៣.៩៣០ក្បាល ជំងឺប៉េស្តទាចំនួន ១១.៧៣៧ក្បាល និងជំងឺអាសន្នរោគចំនួន ៣២.៤១៥ក្បាល។

### ៤.២ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុពេទ្យ

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-ផ្នែកពិនិត្យវត្ថុវិភាគសរុបចំនួន ១៤១សំណាក

-ផ្នែកសរីរពេគសាស្ត្រសរុបចំនួន ១០ក្បាល ។

### ៤.៣ ការអនុវត្តវិធានបសុពេទ្យ

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន ១២ករណី មកពីតាមបណ្តារាជធានី ខេត្ត សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព និងរាយការណ៍ពីបក្សីឈឺ ងាប់

-ចុះបង្ក្រាបបទល្មើសចលនាដឹកជញ្ជូនគោ ក្របីខុសច្បាប់ចំនួន០១ករណី សរុបចំនួន៤៥ក្បាល មាន់សាច់រស់ខុសច្បាប់០១ករណីចំនួន២.២៦៨ក្បាល និងធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន៦លានរៀល

-ចុះបាញ់ថ្នាំសម្លាប់មេរោគ(TH4) នៅតាមកន្លែងចិញ្ចឹមមាន់ ជ្រូក និងទាចំនួន១៦៦លើក កន្លែងពិឃាតមាន់ចំនួន០៧លើក កន្លែងលក់មាន់ចំនួន០៤លើក ទ្រុងចិញ្ចឹមចំនួន០៤លើក បរិវេណភូមិចំនួន១១លើក និងសត្តឃាតដ្ឋានចំនួន២២លើក

-ធ្វើការទប់ស្កាត់ចលនាបក្សីនិងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាង ដោយបានណែនាំប្រជាពលរដ្ឋ និងអាជីវករឲ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី ។

### ៤.៤ ការងារឡជីវឧស្ម័ន

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន ៧១ឡ ។

## ៥ ផ្នែកកៅស៊ូ

### ៥.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០២-២០១១ (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ (តោន) |
|---|---|---|---|---|---|
| *I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ* | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៣៦៧,៧០ | ៣៧០,៧១ | ២០៧,៩៩ | ១៧៤,០០ |
| *សរុប I* | | *៣៦៧,៧០* | *៣៧០,៧១* | *២០៧,៩៩* | *១៧៤,០០* |
| *II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន* | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ៩.៣៥៦,៨៨ | ៦.៦៨៩,៤៤ | ១០.៦២០,១៥ | ៩.៣៧៥,៦៤ |
| ២ | ក្រុមហ៊ុន ស៊ីហ្វ៉ាប់ប៊េលីមីធីត(រតនគីរី) | ៨៦៧,៩៤ | ៩៥៤,៨៩ | ៦៨២,៦៦ | ៥៤០.០០ |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៦៦,៨០ | ៨៨៥,០១ | ៥៧៨,៧២ | ៤៩៤,០០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.០៥៦,៣២ | ៣.២៦៦,៩២ | ១.៨៦៨,៩៣ | ១.៨៦៨,០០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៩៥,៥៨ | ៥.២៥៩.០៨ | ២.៥៦២,១៣ | ២.២០១,៦០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វ៊ីសសស់(ស្នួល) | ១.៥៦១,៨០ | ២.៨២៤,៤១ | ១.៥៦៩,៤៩ | ១.៤៣៤,៥០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប(ពាមជាំង) | ២.២៤៣,២៦ | ១.១៥៧,៦៥ | ៧៤២,៦៧ | ៦៥១,៤០ |

| | | | | | |
|---|---|---|---|---|---|
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.១៣៥,២៩ | ៣.៦៨៧,៥៣ | ៧៩៤,៥៧ | ៦២៤,00 |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | | ១.៥៧០,៦៣ | | |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ២.៨៥២,៧២ | ២.៦១៤,៩៥ | ២.៧១៥,២៦ | ១.៩៨១,៤០ |
| *សរុប II* | | *២៥.៦៣៦,៥៩* | *២៨.៩១០,៥១* | *២២.១៣៤,៥៨* | *១៩.១៧០,៥៤* |
| សរុប I+II | | ២៦.០០៤,២៩ | ២៩.២៨១,២២ | ២២.៣៤២,៥៧ | ១៩.៣៤៤,៥៤ |

**៥.២ ការផ្សព្វផ្សាយនិងបណ្តុះបណ្តាល**

-ចុះទៅក្រុមហ៊ុន ស៊ីហ្វ វីសសស់ លីមីធីត ចម្ការកៅស៊ូស្នួល ខេត្តក្រចេះ ដើម្បីត្រួតពិនិត្យតាមដានមន្ទីរពិសោធន៍មូលដ្ឋាននិងរោងចក្រកែច្នៃកៅស៊ូ CSR

-បន្តដឹកនាំសរសេរសារណាបទរបស់និស្សិតសាកលវិទ្យាល័យស្វាយរៀងចំនួន០២នាក់។

**៥.៣ ការស្រាវជ្រាវអំពីការបង្កាត់ពូជ**

-វាស់ទំហំដើមកៅស៊ូក្នុងឡូត៍ពិសោធន៍ក្លូននៅខេត្តមណ្ឌលគីរី ដែលមានចំនួនដើមសរុបប្រមាណ៣.២០០ដើម លើក្លូនចំនួន៨គឺ GT1, IRCA230, RRIM600, RRIM712, PB217, PB260, PB314, និងRRIC100 នៅលើផ្ទៃដីពិសោធន៍ប្រមាណ៥,៧៦ហិកតា ក្នុងប្លុក៩,១៤A របស់ក្រុមហ៊ុនចម្ការកៅស៊ូ SOCFIN. KCD។

**៥.៤ ការស្រាវជ្រាវអំពីសរីរវិទ្យានិងអាជីវកម្ម**

-ចំពោះពូជ PB217 បច្ច័យ TO (D3): ET 2.5% Pa(250mg) 10/y បានទទួលទិន្នផល ២១,២ក្រាមក្នុងមួយដើមក្នុងមួយពន្លាកខ្ពស់ជាងបច្ច័យ T1 (D4): ET 2.5% Pa(30mg) 12/y បានទទួលទិន្នផល ១៩ក្រាមក្នុងមួយដើមក្នុងមួយពន្លាកខ្ពស់ជាងបច្ច័យ បច្ច័យ T2 (D5): ET 3.3% Pa(396mg) 12/y បានទទួលទិន្នផល ១៩,៣ក្រាមក្នុងមួយដើមក្នុងមួយពន្លាកនិងខ្ពស់ជាងបច្ច័យ និងបច្ច័យ T3 (D6): ET 3.3% Pa(594mg) 18/y បានទទួលទិន្នផល ១៨,៨ក្រាមក្នុងមួយដើមក្នុងមួយពន្លាក។

**៥.៥ ការស្រាវជ្រាវ ការដាំដុះ និងការពារ**

-អនុវត្តការថែទាំក្លូនកៅស៊ូចម្ការពិសោធន៍ IC-2007, IC-2008, T1&T2-2008, T1&T2-2009 planting densities on clone PB260, IRCA230, Fertilizer test on clone PB217, PB330 តាមពិធីសារពិសោធន៍។

**៥.៦ ការងារនៅស្ថានីយអនុវត្ត**

-លាបថ្នាំរំញោចនិងលាបខ្លាញ់គោ

-ដាំថ្មីបានចំនួន ៤១៩ក្លូន

-ដាក់គ្រាប់បណ្តុះក្នុងថង់ធ្វើថ្នាលក្លូន

-ប្រមូលផលជ័រស្ងួតបានចំនួន៣៣,០២៧តោន។

**៥.៧ ការងារក្នុងមន្ទីរពិសោធន៍យថាប្រភេទ**

-ធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន១៨ភាគសំណាក ដើម្បីបញ្ជាក់គុណភាពការកែច្នៃរបស់រោងចក្រនិងគុណភាពកែច្នៃកៅស៊ូសន្លឹក RSS (Ribbed Smoked Sheet)

-ចុះបេសកកម្មនៅក្រុមហ៊ុន ស៊ីហ្វ វីសសស់ ខេមបូឌា លីមីធីត ចម្ការកៅស៊ូស្នួល ដើម្បីចុះត្រួតពិនិត្យ តាមដានរោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍មូលដ្ឋាន។

## ៦ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា *ក្នុងខែចំនួន២០៦ច្បាប់* សរុបចំនួន៣.៧៨៦ច្បាប់ ទទួលពីអង្គភាពក្រោម

និវាទ *ក្នុងខែចំនួន៤៩២ច្បាប់* សរុបចំនួន២.៧៥៦ច្បាប់ និងទទួលពីរាជធានី ខេត្ត *ក្នុងខែចំនួន៧៤ច្បាប់* សរុបចំនួន៧០៧ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត *ក្នុងខែចំនួន៨២៥ច្បាប់* សរុបចំនួន៥.៨១០ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ *ក្នុងខែចំនួន៣៦ច្បាប់* សរុបចំនួន៣៥៤ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ *ក្នុងខែចំនួន១៤ច្បាប់* សរុបចំនួន៦៤២ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៧ ផ្នែកនីតិកម្មកសិកម្ម

### ៧.១ ការងារអាជីវកម្មសម្ភារកសិកម្ម

-ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មបានចំនួន០២ក្រុមហ៊ុន

-ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មនិងកម្រៃសេវាសាធារណៈបានចំនួន០៦ក្រុមហ៊ុន សម្ភារកសិកម្មចំនួន២៤មុខ សេវាវិភាគជីកសិកម្មចំនួន០៦ក្រុមហ៊ុន ស្មើនឹងចំនួន១៩សំណាក សេវានាំចូលសម្ភារកសិកម្មចំនួន០៩ក្រុមហ៊ុន និងបានប្រមូលកម្រៃសេវាសាធារណៈសរុប ៩.៨០០.០០០រៀល

-ផ្តល់លិខិតអនុញ្ញាតនាំចេញ នាំចូលសម្ភារកសិកម្មចំនួន១០ក្រុមហ៊ុន ក្នុងនោះថ្នាំកសិកម្មចំនួន៤៣មុខ ស្មើនឹង២២៥តោន ជីកសិកម្មចំនួន២៣មុខ ស្មើនឹង៣៧.៤០០តោន ចំណីសត្វចំនួន៣៧មុខ ស្មើនឹង៨.៨៩៥តោន និងបសុឱសថចំនួន៣៨មុខ ស្មើនឹង១០៥តោន។

### ៧.២ ការងារមន្ទីរពិសោធន៍

-ទទួលវិភាគលើសំណាកជីកសិកម្មបានចំនួន០៥ក្រុមហ៊ុន សរុបចំនួន១៣សំណាក

-ចុះបញ្ជិកាថ្នាំកសិកម្មចំនួន០១ក្រុមហ៊ុន ស្មើនឹងចំនួន៧១មុខ ជីកសិកម្មចំនួន០៩ក្រុមហ៊ុន ស្មើនឹង៤៧មុខ និងបសុឱសថចំនួន០១ក្រុមហ៊ុន ស្មើនឹង៦៧មុខ។

### ៧.៣ ការងារវិធានកសិកម្មនិងស្រាវជ្រាវ

-ចុះត្រួតពិនិត្យការនាំចូលសម្ភារកសិកម្មចំនួន០៣ក្រុមហ៊ុន

-ចុះត្រួតពិនិត្យមូលដ្ឋានអាជីវកម្មសម្ភារកសិកម្មចំនួន០២ខេត្ត សរុបចំនួន១៣ករណី និងចាត់វិធានការច្បាប់ចំនួន២៣ករណី។

### ៧.៤ ការងារផ្សព្វផ្សាយ

-ធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីបទដ្ឋានគតិយុត្តនិងនីតិវិធីក្នុងការគ្រប់គ្រងសម្ភារកសិកម្មចំនួន០២លើក នៅខេត្តបាត់ដំបងនិងខេត្តបន្ទាយមានជ័យ។

## ៨ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

-ចូលរួមដេញថ្លៃលក់នូវទ្រព្យសម្បត្តិចាស់ ខូច ទ្រុឌទ្រោមប្រើប្រាស់លែងកើតដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ និងនាយកដ្ឋានកិច្ចការរដ្ឋបាល

-ចុះពិនិត្យនិងវាយតម្លៃគុណភាពបច្ចេកទេសនូវទ្រព្យសម្បត្តិរដ្ឋរបស់រោងចក្របង្កកជលផល I ផ្សារដេប៉ូ នៃរដ្ឋបាលជលផល និងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល

-រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៣ បញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីដាក់ឲ្យដំណើរការដេញថ្លៃជាសាធារណៈ

-ធ្វើលិខិតអន្តរគមន៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំណើសុំថវិកាចំនួន៣០.៨៦១,៨២រៀល ដើម្បីបំពេញចូលគណនី Sub-Designated Account នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រនិងបង្កើនផលិតភាពកសិកម្ម (RIAPIP)

-ធ្វើលិខិតអន្តរគមន៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ករណីរដ្ឋបាលព្រៃឈើ "គម្រោងរបៀងអភិរក្សជីវចម្រុះមហា

អនុតំបន់មេគង្គ" សំណើសុំបំពេញឡើងវិញថវិកាចំនួន៨៣.៤២៧,៩១ដុល្លារអាមេរិក ក្រោមជំនួយហិរញ្ញប្បទានឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ី ADB

-ផ្ញើលិខិតអន្តរាគមន៍ទៅឯកឧត្តមអគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំណើសុំថវិកាបុរេប្រទានចំនួន ៥.០០០ដុល្លារអាមេរិក សម្រាប់តម្កល់ប្រើប្រាស់នៅក្នុងគណនី Imprest Account នៃគម្រោង PFM for Rural Development Project ក្រោមជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB TA Grant No.0222-CAM/Component1

-គណនីនៅតាមធនាគាររដ្ឋនិងធនាគារពាណិជ្ជនានាសរុបចំនួន ២៦គណនី (NBC: ៦, FTB: 11, ACLEDA: ៧, ANZ: 2)

-បានទទួលបង្កាន់ដៃប្រាក់កក់ធានាអនុវត្តកិច្ចសន្យាចំនួន០១ក្រុមហ៊ុន គឺក្រុមហ៊ុន ហេង ហ៊ាប អ៊ិនវេសមេន ។

## ៩ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ចុះពិនិត្យស្ថានភាពស្រូវស្រាលដើមរដូវវស្សាដែលកំពុងលិចលង់ដោយជំនន់ទឹកភ្លៀងជាង៣០០ហិកតា និងសំណេះសំណាលជាមួយកសិករចំនួន១០០នាក់ នៅសង្កាត់អូរគន្ធរ ក្រុងស្ទឹងសែន និងពិនិត្យមើលការផលិតស្រូវពូជផ្ការំដួលនៅស្ថានីយបល្ល័ង្គ សង្កាត់ដីរីជាន់ខ្លា ក្រុងស្ទឹងសែន

-ពិនិត្យមើលការធ្វើកសិកម្មចម្រុះរបស់សហគមន៍ព្រៃឈើក្បាលបីនិងជួបសំណេះសំណាលជាមួយសហគមន៍ចំនួន១០០នាក់ នៅឃុំទីពោធិ៍ ស្រុកសន្ទុក ខេត្តកំពង់ធំ

-ចុះពិនិត្យឃ្លាំងស្តុកស្រូវពូជនិងឡសម្ងួតនៅស្ថានីយពោធិ៍លាស់ និងជួបសំណេះសំណាលជាមួយសហគមន៍ពោធិ៍លាស់សែនមានជ័យចំនួន៥០នាក់ នៅក្នុងឃុំក្រាំងស្វាយ ស្រុកព្រះស្តេច ខេត្តព្រៃវែង

-ពិនិត្យស្រូវពង្រោះប្រមាណ១.០០០ហិកតា នៅសហគមន៍អភិវឌ្ឍន៍កសិកម្មពន្លឺកសិករអូររំចេក ដោយប្រើពូជក្រអូបនៅឃុំត្រពាំងជង ស្រុកបាកាន និងពិនិត្យមើលស្រូវផ្ការំដួលនិងស្រូវរបស់កសិករនៅឃុំស្វាយលួង ស្រុកកណ្តៀង

-ចុះពិនិត្យស្រូវប៉ះពាល់១៨២ហិកតា និងខូចខាត៩៣ហិកតា នៅភូមិប្រហូត ឃុំដីរីផុង ស្រុកឆ្លូង និងពិនិត្យមើលពោតខូចខាតដោយទឹកជំនន់ជាង៣០ហិកតា នៅភូមិព្រៃកតាអំ ឃុំបុស្សលាវ ស្រុកចិត្របុរី

-ចូលរួមប្រជុំរបស់គម្រោងស្បៀងអាហារនៃគម្រោងសហប្រតិបត្តិការត្រីភាគីចិន-កម្ពុជា-UNDP លើការបង្កើនផលិតភាពដំណាំដំឡូងមីវគ្គ២ នៅសណ្ឋាគារកាំបូឌីយ៉ាណា

-ចូលរួមសិក្ខាសាលាបើកដំណើរការគម្រោងស្តីពីការកាត់បន្ថយការបាត់បង់ជីជាតិនៅតំបន់ខ្ពង់រាប ដោយប្រើប្រាស់ប្រព័ន្ធដាំដុះដំណាំបង្វិលនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង

-បន្តការងារពិសោធន៍ស្រាវជ្រាវនៅក្នុងវិទ្យាស្ថាននិងតាមរាជធានី ខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា

-រៀបចំធ្វើទិវាស្រែបង្ហាញអំពីម៉ាស៊ីនដាំគ្រាប់ពូជស្ងួតក្នុងលក្ខខណ្ឌដីទំនាបអាស្រ័យស្រែទឹកភ្លៀង នៅខេត្តតាកែវ និងខេត្តកំពត និងចុះប្រមូលផលពិសោធន៍ស្រូវដើមរដូវវស្សា

-ចុះជ្រើសរើសកន្លែងពិសោធន៍ស្រាវជ្រាវលើគម្រោង CSE-37 នៅខេត្តតាកែវ

-ចុះប្រមូលទិន្នន័យពីការប្រើប្រាស់ជីរបស់កសិករលើដំណាំកសិកម្មនៅខេត្តកំពង់ឆ្នាំង

-បន្តបញ្ចូលទិន្នន័យនិងសរសេររបាយការណ៍ស្រាវជ្រាវប្រចាំឆ្នាំ២០១៣។

## ១០ សាលាជាតិកសិកម្មព្រែកលៀប

### ១០.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៧២នាក់(ស្រី៥១៣នាក់)ក្នុងនោះ÷

• និស្សិតអាហារូបករណ៍ចំនួន១.២០៥នាក់ ក្នុងនោះស្រី៤៣៨នាក់ ÷

-ថ្នាក់បរិញ្ញា ៩៦២នាក់ (ស្រី ៣៨៧នាក់ )សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង ២៤៣នាក់ (ស្រី ៩១នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម ជលផល កសិឧស្សាហកម្ម និងសុរិយោដី។

• និស្សិតបង់ថ្លៃចំនួន១៩៦នាក់ ក្នុងនោះស្រី២៧នាក់ ÷

-ថ្នាក់បរិញ្ញា ១៥៤នាក់ (ស្រី ២៤នាក់ )សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង ៤២នាក់ (ស្រី ០៣នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល និងផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ។

• និស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យចំនួន១៧១នាក់ ក្នុងនោះ ស្រី៤៨នាក់ ÷

-ថ្នាក់បរិញ្ញា ១៣៨នាក់ (ស្រី ៤២នាក់) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ និងសុរិយោដី

-ថ្នាក់បរិញ្ញារង ៣២នាក់ (ស្រី ០៦នាក់) សិក្សាលើមុខជំនាញផលិតកម្មនិងបសុព្យាបាល ។

**១០.២ ការងារផលិតកម្មនិងស្រាវជ្រាវ**

-កសិដ្ឋានដំណាំលម្អបានដាំផ្កា ឈើពណ៌ ដូងតាំង និងពង្រីកពូជបន្ថែមសម្រាប់ការអនុវត្តនិងដាំលម្អក្នុងបរិវេណសាលាជាតិ បណ្តុះកូនក្លូន ស្លាកន្ទុយកំប្រុក

-បើកវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់និងចិញ្ចឹមជ្រូក ដែលមានសិក្ខាកាមចូលរួមចំនួន២០នាក់ ក្នុងនោះស្ត្រីចំនួន០៣នាក់

-បើកវគ្គបណ្តុះបណ្តាលស្តីពីដំណាំកៅស៊ូនិងឈើហូបផ្លែ ដែលមានសិក្ខាកាមចូលរួមចំនួន០៥នាក់ ក្នុងនោះស្ត្រី ០១នាក់។

## ១១ សាលាជាតិកសិកម្មកំពង់ចាម

**១១.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៥៩នាក់(ស្រី៦០៨នាក់) ក្នុងនោះ ÷**

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់)ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី ៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន ១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ ។

**១១.២ ការងារពិសោធន៍ស្រាវជ្រាវ**

-ធ្វើការពិសោធន៍ដំណាំសណ្តែកសៀង

-ធ្វើការពិសោធន៍លើប្រសិទ្ធភាពជីអាសូត ផូស្វរ ប៉ូតាស្យូម លើការលូតលាស់ដំណាំម្ទេសដៃនាង

-ពិសោធន៍តាមដានការលូតលាស់ជ្រូកមេក្នុងការចិញ្ចឹមតាមរយៈការប្រើប្រាស់ចំណីឧស្សាហកម្ម។

**១១.៣ ការងារស្រាវជ្រាវ ផ្សព្វផ្សាយ និងការផ្ទេរបច្ចេកវិជ្ជាកសិកម្ម**

-លើកគម្រោងចំនួន១១ស្នើសុំថវិកាសម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទស្តីពីការពិសោធន៍កសិកម្ម វារីវប្បកម្ម បសុវប្បកម្ម និងសង្គមជនបទ

-បន្តការងារស្រាវជ្រាវផលិតកម្មដំណាំស្រូវ ដែលបានឧបត្ថម្ភជំនួយពី ACIAR-CARF

-បន្តការងារស្រាវជ្រាវលើបសុវប្បកម្ម ដែលបានឧបត្ថម្ភជំនួយពី DEL-phe(UK)

-ផ្សព្វផ្សាយពីការធ្វើឥណទានស្រូវពូជ ជ្រូកពូជ និងចាក់វ៉ាក់សាំងការពារជំងឺសត្វគោ-ក្របី នៅតាមមូលដ្ឋានឃុំ-ស្រុក ក្នុងខេត្តកំពង់ចាម

-ផ្តល់ជ្រូកពូជជូនដល់កសិករក្រីក្រនៅស្រុកត្រាំកក់ខេត្តតាកែវនិងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមបានចំនួន១៨គ្រួសារ

-ធ្វើការប្រជុំកសិករណែនាំពីការប្រើប្រាស់ថ្នាំពុលគីមី ជីគីមី និងជីសរីរាង្គ នៅក្នុងមូលដ្ឋានស្រុកត្រាំកក់ ខេត្តតាកែវ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

## ១២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

-និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៦៥៧នាក់ (ស្រី១.២៣៣នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកៅស៊ូ ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន២៥លើក និងក្រៅប្រទេសចំនួន២១លើក និងសិក្ខាសាលាក្នុងប្រទេសចំនួន២៤លើក និងក្រៅប្រទេសចំនួន២២លើក

-បញ្ជូននិស្សិតទៅចូលរួមវគ្គបណ្តុះបណ្តាលនិងកម្មសិក្សានៅក្រៅប្រទេសចំនួន១២នាក់ និងមន្ត្រីរាជការចំនួន ១២នាក់

-បញ្ជូននិស្សិតទៅធ្វើកម្មសិក្សានៅប្រទេសអ៊ីស្រាអែលចំនួន៣០នាក់

-អនុវត្តគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ចំនួន២៣គម្រោង គម្រោងទាំងនោះមានគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ចម្រុះជំនាញផ្នែកវិទ្យាសាស្ត្រកសិកម្ម ផ្នែកវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ ផ្នែកវិទ្យាសាស្ត្រព្រៃឈើ ផ្នែកវិទ្យាសាស្ត្រជលផល ផ្នែកស្រាវជ្រាវ-ផ្សព្វផ្សាយ ផ្នែករៀបចំដែនដីនិងរដ្ឋបាលដីធ្លី

-ធ្វើការផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមករវាងសាស្ត្រាចារ្យនិងនិស្សិត ព្រមទាំងខិតខំពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិយ៉ាងទូលំទូលាយ ក្នុងទិសដៅពង្រឹងគុណភាពអប់រំឱ្យបានល្អប្រសើរដើម្បីឱ្យមានលក្ខណៈប្រកួតប្រជែង

-បញ្ជូននិស្សិតចុះជួយវាស់វែងដីធ្លីជូនប្រជាជន ដើម្បីចូលរួមអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីរបស់រាជរដ្ឋាភិបាលចំនួន៤២៩នាក់ មកពីមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកសិកម្ម និងសេដ្ឋកិច្ចកសិកម្មនិងជនបទ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៣នេះមានសភាពលឿនជាងឆ្នាំមុន បើប្រៀបធៀបរយៈពេលដូចគ្នា។ ប្រជាកសិករកំពុងខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាប-ព្រោះ និងដក-ស្ទូង ដើម្បីឱ្យទាន់រដូវកាលដាំដុះ។

## IV- ទិសដៅ

-ជំរុញការងារបង្កប ង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៣ និងការប្រមូលផលស្រូវស្រាលដើមរដូវ

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ និង ០២

-បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឱ្យមានការចូលរួម

ប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ ហើយត្រូវសម្រេចឱ្យបានប្រវែង ១.០០០គីឡូម៉ែត្រ

-ជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន ១០០កន្លែងបន្ថែមទៀត

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយពីសារប្រយោជន៍ស្តីពីព្រៃឈើ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេស

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះដេញថ្លៃផល អនុផលព្រៃឈើដែលរឹបអូសដោយសាលក្រម ដីកាសម្រេច ពិន័យអន្តរការណ៍ និងឈើអញ្ញាតជន(ឈើគ្មានម្ចាស់)នៅទូទាំងប្រទេស

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឱ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសន្និធិផល អនុផលព្រៃឈើ

-បន្តត្រួតពិនិត្យបទល្មើសនេសាទទឹកសាបក្នុងរដូវបិទនេសាទនៅរាជធានី ខេត្តឱ្យកាន់តែមានប្រសិទ្ធភាព

-បន្តការតាមដានសកម្មភាពអាជីវកម្មនេសាទសមុទ្រ

-បន្តការងារផ្សព្វផ្សាយការអភិវឌ្ឍវិស័យវារីវប្បកម្មនិងការគ្រប់គ្រងធនធានជលផល

-បន្តការងារស្រាវជ្រាវដើម្បីកំណត់អត្តសញ្ញាណកូនត្រីទៅតាមប្រភេទនីមួយៗនៅតាមដងទន្លេមេគង្គ

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សីនិងជំងឺផ្តាសាយ (A) H1N1

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនបៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី ១០៥ ជាមួយ IRA

-អង្កេតទូទៅស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-ពង្រឹងការងារបញ្ជិកាគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិង បណ្តាមន្ទីរកសិកម្មរាជធានី ខេត្ត

-បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំឯកសារាចរ សេចក្តី

ណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឲ្យល្អប្រសើរ តាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា

-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិក្នុងវិស័យកសិកម្មឲ្យបានទូលំទូលាយជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់លិខិតបទដ្ឋានគតិយុត្ត និងអត្ថបទក្រោមច្បាប់តាមអនុវិស័យ ដើម្បីដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៧ ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**